ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៩៥

ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០១

សាលដីកា

លេខ : ១៣០

ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ៣០ - ខែ ឧសភា ឆ្នាំ ២០០២ ដោយមានសមាសភាពដូចតទៅ:-

១-ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២-លោក ជីវ កេង ជាចៅក្រម

៣-លោក ប្រាក់ គឹមសាន ជាចៅក្រមរបាយការណ៍

៤-លោក យស់ សួនខ្វឺន ជាចៅក្រម

៥-លោក គង់ ភីរុន ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី ឃុត សុគន្ធា

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ៥៨ "ឃ" ចុះថ្ងៃទី ១៧-៧-០១ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ១៥៦ ចុះថ្ងៃទី ០១-០៣-០១ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ ចេង ផាម៉ារី ផ្ទេរសិទ្ធិអោយលោកចាន: សូរីះ "ជាដើមបណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅផ្ទះ-លេខ ៥២ខេ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ចាត សួ "ស" ម្តាយឈ្មោះ កុង សូផានី "រ" ។

- ដើមចោទឈ្មោះ សឹង្ហ គីលីម "ជាដើមបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីសាលាស្រុកខ្សាច់កណ្តាល ទីលំនៅផ្ទះលេខ ៩៣អឺ១ហេនូត សង្កាត់ផ្សារ-ចាស់ ខណ្ឌដូនពេញ ។ ឪពុកឈ្មោះ សឹង្ហ កិ "រ" ម្តាយឈ្មោះ ថុង ភ្លុក "រ" ។

និងចុងចម្លើយឈ្មោះ ឆាយ បូរណ្ណ ផ្ទេរសិទ្ធិអោយ ជ័យ ស៊ាន "ដើមបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរនគរបាលនាយកដ្ឋានជនបរទេស ទីលំនៅផ្ទះលេខ ៨៩អឺ២ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ជ័យ នុច "ស" ម្តាយឈ្មោះ គង់ យៀង "រ" ។

កម្មវត្ថុ : ទំលោភលើផ្លូវសាធារណៈ

តាមបណ្ដឹងសាទុក្ខលេខ ២៤៦ ចុះថ្ងៃទី ២៤_៧_០១ របស់លោក ជ័យ ស៊ាន ប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ ៤៨ "ឃ" ចុះថ្ងៃទី ១៣_០៧_០១ របស់សាលាឧទ្ធរណ៍លើសេចក្ដីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៩៨ ចុះថ្ងៃទី ០៦_១១_០១ របស់តុលាការ_កំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ២៤_៨_០០ របស់ឈ្មោះ ចេង ផាម៉ាធី និងពាក្យបណ្ដឹងចុះថ្ងៃទី ២៥_១០_០០ របស់ឈ្មោះ សឹង្ហ គីលីម បញ្ជាក់ថា :_ ឈ្មោះ ឆាយ បូរ៉ណ្ណ មានទំនាស់ជាមួយអ្នកជិតខាង ដោយឈ្មោះនេះរំលោភយកផ្លូវសាធារណៈ មកប្រើជាប្រយោជន៍ផ្ទាល់_ខ្លួន ធ្វើអោយប៉ះពាល់ដល់ប្រយោជន៍អ្នកដទៃ ដោយដាក់គំនរឧសធ្យូង និង សំភារៈផ្សេងៗដទៃទៀតនៅលើផ្លូវ បណ្ដាលអោយផ្លូវនោះមិនអាចចរាចរបាន បិទផ្លូវចូលទៅបង្គន់ និង តយ៉ាកមកលើផ្លូវទៀតផង ។

បានឃើញសាលក្រមលេខ ៥៦ "ជ" ចុះថ្ងៃទី ២៩_១២_០០ របស់តុលាការក្រុង_ភ្នំពេញ ដែលសំរេចដូចតទៅ :_

១_ទទួលពាក្យបណ្ដឹងរបស់ដើមចោទ ចុះថ្ងៃទី ២៤_៨_០០ និង ចុះថ្ងៃទី២៥_១០_០០ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២_ទទួលពាក្យបណ្ដឹងតបរបស់ឈ្មោះ ឆាយ បូរ៉ណ្ណ ចុះថ្ងៃទី ៣១_៨_០០ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយផ្ទុយនឹងគតិច្បាប់ ។

៣_បង្គាប់អោយឈ្មោះ ឆាយ បូរ៉ណ្ណ រុះរើសំយ៉ាបស័ង្កសីផ្ទះរបស់ខ្លួនចំនួន ២កន្លែង គឺ :_

ក_បំពង់ផ្សែង និង សំយ៉ាបស័ង្កសីដែលប្រក់លយមកលើដំណើរប្រើប្រាស់រួមរបស់ឈ្មោះ ចេង ផាម៉ាធី និង ឈ្មោះ សឹង្ហ គីលីម ចាប់ពីថ្ងៃនេះតទៅ ។

ខ_សំភារៈផ្សេងៗ និង សំយ៉ាបស័ង្កសី ដែលប្រក់គ្របលើផ្លូវសាធារណៈ ដែលចេញទៅផ្លូវលេខ ១៥ ចាប់ពីថ្ងៃនេះតទៅ ។

៤_បង្គាប់អោយឈ្មោះ ឆាយ បូរ៉ណ្ណ រើយកឧសធ្យូង និង សំភារៈផ្សេងៗដែលមានទាំងប៉ុន្មានចេញពីមុខបង្គន់ និង ផ្លូវចូលបង្គន់ដែលប្រើប្រាស់រួមរបស់ឈ្មោះ ចេង ផាម៉ាធី និងឈ្មោះ សឹង្ហ គីលីម អោយអស់ ចាប់ពីថ្ងៃនេះតទៅ ។

៥_រក្សាទុកផ្លូវទំនាស់ទំហំ ១,៨០ម គុណ ៤,១០ម និង ទំហំ ២,៤០ម គុណ ៩,៤០ម ជាផ្លូវសាធារណៈតទៅ ។

៦_អោយឈ្មោះ ឆាយ បូរ៉ណ្ណ សងជម្ងឺចិត្តចំនួន ១.០០០ដុល្លា "មួយពាន់ដុល្លាអាមេរិក" អោយទៅឈ្មោះ ចេង ផាម៉ាធី និង ចំនួន ១.០០០ដុល្លា "មួយពាន់ដុល្លាអាមេរិក" អោយទៅឈ្មោះ សឹង្ហ គីលីម ចាប់ពី សាលក្រម ចូលជាស្ថាពរ ។

៧_រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ៧.០០០រ,០០ ដែលដើមចោទបានបង់ទុកជាស្រេច

កាលបើសាលក្រមចូលជាស្ថាពរ បង្គាប់អោយចុងចម្លើយ បង់សងទៅដើមចោទវិញជាក្រោយ ។

៨_សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ចាប់ពីថ្ងៃប្រកាសសាលក្រម ។

សាលក្រមនេះត្រូវបានឈ្មោះ ជ័យ សារិន ប្តឹងឧទ្ធរណ៍តាមបណ្តឹងចុះថ្ងៃទី០២_០២_០១ លើសេចក្តីសំរេចទាំងមូល ។

និងឈ្មោះ ចាត សុវីរៈ និង ឈ្មោះ សុឹង្ហ គីលីម ប្តឹងឧទ្ធរណ៍តាមបណ្តឹងចុះថ្ងៃទី០៦_០២_០១ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីកា លេខ ៤៨ "ឃ" ចុះថ្ងៃទី ១៧_៧_០១ របស់ សាលាឧទ្ធរណ៍ដែល_សំរេចដូចតទៅ :_

១_ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ជ័យ សារិន ចុះថ្ងៃទី ០២_០២_០១ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២_ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ចាត សុវីរៈ និង ឈ្មោះ សុឹង្ហ គីលីម ចុះថ្ងៃទី ០៦_០២_០១ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

៣_តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៥៦ "ដ" ចុះថ្ងៃទី ២៩_១២_០០ របស់តុលាការ_ក្រុងភ្នំពេញទុកជាបានការ ។

៤_បង្គាប់អោយដាក់គុកបង្ខំរូបកាយ ដើម្បីធានាសំណងអន្តរាយ កាលបើចុងចម្លើយឈ្មោះ នាយ បូរ៉ណ្ណ រឹងរូសមិនព្រមសង តាមបញ្ញត្តិមាត្រា ១៣៣ នៃ ច្បាប់ស្តីពីនីតិវិធីអនុ_វត្តសាលក្រមរដ្ឋប្បវេណី ។ សំណូមពរលើសពីនេះបដិសេធចោល ។

៥_កាត់យកប្រាក់ប្រដាប់ក្តីដាក់សាលាឧទ្ធរណ៍ចំនួន២៦.០០០រ,០០ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់ទុករួច គឺពន្ធចុះបញ្ជីក្តី ពន្ធថ្លឹង....រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រ,០០ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០រ,០០ និង ចំណាយលើអាជ្ញាធរតុលាការ ១៨.០០០រ,០០ សរុប ២៦.០០០រ,០០ ។

បង្គាប់អោយឈ្មោះ នាយ បូរ៉ណ្ណ សងប្រាក់ប្រដាប់ក្តីចំនួន ១៣.០០០រ,០០ អោយទៅដើមចោទវិញ ។

៦_សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៤៦ ចុះថ្ងៃទី ២៤_៧_០១ របស់លោក ជ័យ សារិន ធ្វើទៀងក្នុងកំណត់ច្បាប់ ។

បានឃើញសារណារបស់លោក នាយ បូរ៉ណ្ណ ចុះថ្ងៃទី ២០_១១_០១ ។

បានឃើញសារណាតបរបស់លោក ចាត សុវីរៈ និង ឈ្មោះ សុឹង្ហគីលីម ចុះថ្ងៃទី ២៩_១១_០១ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា:_សាលដីកាសាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

បានស្តាប់ចម្លើយរបស់លោក ជ័យ ស៊ាន ដែលបានឆ្លើយនៅពេលសវនាការថា:_ តុលាការក្រុងក៏ដូចជាសាលាឧទ្ធរណ៍កាត់មិនត្រឹមត្រូវទេ ។ លោក ផាវ ណាំ ជាម្ចាស់ផ្ទះដំបូងបានបាញ់ព្រះរំលោភមកលើគ្រួសាររបស់ខ្លួន នៅពេលដែលគ្រួសារខ្លួនហាមឃាត់មិនអោយធ្វើជណ្តើរ ព្រោះជណ្តើរនេះធ្វើចុះមកលើដីខ្លួន ។ នៅឆ្នាំ ១៩៩៦ លោក ផាវ ណាំ បានលក់មកអោយលោក ចេង ផាម៉ាឌី ដល់ឆ្នាំ ២០០០ លោក ចេង ផាម៉ាឌី ក៏ដាក់ពាក្យប្តឹងខ្លួនម្តង ។ តាមពិតជណ្តើរគេអនុញ្ញាតអោយធ្វើនៅខាងក្រោយ មិនមែនចំពៀងផ្ទះទេ ។ ឯលោក គីលីម មិនមែនជាប្រជាជនរស់នៅក្នុងសង្កាត់នេះទេ ហេតុអ្វីមានសិទ្ធិប្តឹងខ្លួន ។

បានស្តាប់ចម្លើយរបស់លោក ចាត សូរីរ: ដែលបានឆ្លើយនៅពេលសវនាការថា:_ យ៉ាបហ៊ីប្រូហ្ស៊ីសង់គ្របលើជណ្តើរ មានទាំងបំពង់បង្ហូរដែកនៅឯបជណ្តើរនោះទៀត អាចអោយក្មេងរលាកបាន ហើយនៅតាមឧឡឹងដែលមានសន្ទូដែកខ្ទះខ្លាញ់ ឆ្នាំងបាយចង្ក្រាន និងចានក្បានដាក់នៅពាសពេញ រកផ្លូវដើរមិនបានទេ ។

បានស្តាប់ចម្លើយរបស់លោក សឹង្ហ គីលីម ដែលបានឆ្លើយនៅពេលសវនាការថា:_ ខ្លួនគ្មានឈ្មោះនៅទីនោះមែន តែខ្លួនមានអំណោយផ្ទះពីបង គឺ ផ្ទះលេខ ៩៣អ៊ី១ហេ្វត ជាន់ទី១ នៅខាងក្រោយ ។

នៅឆ្នាំ ១៩៨៥ បងខ្លួនឈ្មោះ សឹង្ហ សារ៉ាត់ បានទៅរស់នៅសហរដ្ឋអាមេរិក គាត់ក៏ប្រគល់អោយខ្លួន ផ្ទះនោះមានទំហំប្រហែលបួនម៉ែត្របួនជ្រុង និង យី ប្រហែល ៣ម៉ៗ

ផ្ទះនេះធ្វើនៅជំនាន់បារាំង វាពុកទ្រុឌទ្រោមខ្លាំងណាស់បច្ចុប្បន្នកូនត្រូវមករៀនបន្តនៅភ្នំពេញ ខ្លួនក៏ត្រូវជួសជុលផ្ទះនោះដើម្បីអោយកូនស្នាក់នៅ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៤៦ ចុះថ្ងៃទី ២៤_០៧_០១ របស់លោក ជ័យ ស៊ាន ធ្វើទៀងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។
- យល់ឃើញថា លោក ចាត សូរីរ: តំណាងអោយលោក ចេង ផាម៉ាឌី

និងលោក សឹង្ហ គីលីម បានសុំដកបណ្តឹងសាទុក្ខរបស់ខ្លួនវិញតាមពាក្យបណ្តឹងចុះថ្ងៃទី២៦_៥_០២ រួចហើយ ដូច្នេះតុលាការកំពូល គប្បីអនុញ្ញាតតាមសុំ ។

- យល់ឃើញថា ការលើកឡើងរបស់លោក ជ័យ ស៊ាន ក្នុងសារណាចុះថ្ងៃទី_១៦_០១_០២ ថាការដែលតុលាការក្រុងភ្នំពេញ ក៏ដូចសាលាឧទ្ធរណ៍ដែរ ដែលសំរេចអោយរក្សាទុកជណ្តើរ សង់ដោយបំពានអោយភាគីដើមចោទប្រើប្រាស់គឺមានភាពលំអៀងនោះ គឺជាការពុំត្រឹមត្រូវទេឡើយ ពីព្រោះថា:-

• ជណ្តើររបស់ដើមចោទត្រូវបានគណកម្មាធិការប្រជាជនក្រុងភ្នំពេញអនុញ្ញាតអោយសាងសង់តាមលិខិតលេខ ៣៤៩ ឆ_ត ចុះថ្ងៃទី ១៤_០២_៨១ និង ក្រោយមកប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ និង មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីរាជធានីភ្នំពេញ សំរេចអោយរក្សាទុកប្រើប្រាស់ដដែលតាមលិខិតលេខ ២៣៤៧ សណន.ស ចុះថ្ងៃទី ១១_៨_០០ និង លិខិតលេខ ២៤៣៨ ដនសស. សណ ចុះថ្ងៃទី ១៨_៨_០០ ។

- យល់ឃើញថា ការដែលតុលាការក្រុងភ្នំពេញ និង សាលាឧទ្ធរណ៍សំរេចអោយឈ្មោះ ឆាយ បូវ៉ណ្ណ រុះរើបំពង់ដែផ្ទង សំយ៉ាបស័ង្កសី ដែលប្រកលើជណ្តើរ និង អោយរុះរើឧស ធ្យូង និង សំភារះផ្សេងៗចេញពីមុខបង្គន់ និង ផ្លូវចូលបង្គន់ព្រមទាំងអោយសងជម្ងឺចិត្តម្នាក់ ១.០០០ដុល្លារអាមេរិកពុំទាន់មានសំអាងហេតុគ្រប់គ្រាន់ទេ ពីព្រោះតុលាការពុំបានពិចារណាអំពីកិរិយាកាន់កាប់របស់លោក ឆាយ បូវ៉ណ្ណ ដែលបានកាន់កាប់ និង ប្រើប្រាស់ទីតាំងទាំងនេះតាំងពីឆ្នាំ ១៩៨០_៨១ រហូតមក ហើយពុំបានពិចារណាអំពីកិរិយាកាន់កាប់បង្គន់របស់ដើមចោទទេ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៤៨ "ឃ" ចុះថ្ងៃទី ១៧_៧_០១ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណះត្រឹមត្រូវតាមទម្រង់ និង នីតិច្បាប់ហើយ លើកលែងតែចំណុចទី៣ "ក" , ៤ ចំណុចទី៥ត្រង់រស្សីផ្លូវទំហំ ១ ,៨០ម គុណ ៤ ,១០ម ប្រើប្រាស់រួម និង ចំណុចទី៦ នៃ សាលក្រមលេខ ៥៦ "ជ" ចុះថ្ងៃទី២៨_១២_២០០០ របស់ តុលាការក្រុងភ្នំពេញ ដែលសាលាឧទ្ធរណ៍បានតម្កល់ទុកជាបានការ និង ចំណុចទី៤ នៃ សាលដីកា របស់ សាលាឧទ្ធរណ៍ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី.

១_ទទួលពាក្យសុំដកបណ្តឹងសាទុក្ខចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០២ របស់លោក ចាត សូរីរៈ និង លោក សឹង្ហ គីលីម ទុកជាត្រឹមត្រូវតាមច្បាប់ ។

២_អនុញ្ញាតអោយលោក ចាត សូរីរៈ និង លោក សឹង្ហ គីលីម

ដកបណ្តឹងសាទុក្ខវិញតាមសុំ ។

៣_ទទួលបណ្តឹងសាទុក្ខលេខ ២៤៦ ចុះថ្ងៃទី ២៤_៧_០១ របស់លោក_ ជ័យ ស៊ាន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិ_ ច្បាប់ខ្លះ ។

៤_តម្កល់សាលដីការដ្ឋប្បវេណីលេខ ៤៨ "ឃ" ចុះថ្ងៃទី ១៧_៧_០១ របស់ សាលាឧទ្ធរណ៍ទុកជាបានការលើកលែងតែចំណុចទី៣ "ក" ,៤ ចំណុចទី៥ ត្រង់រក្សាផ្លូវទំហំ _ ១,៨០ម គុណ ៤,១០ម ប្រើប្រាស់រួម និង ចំណុចទី៦ នៃ សាលក្រមតុលាការក្រុងភ្នំពេញ និង ចំណុចទី៤ នៃ សាលដីការបស់សាលាឧទ្ធរណ៍ដែលត្រូវទុកជាមោឃៈ ។

៥_បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២៩៩ ចុះថ្ងៃទី ០៦_១១_០១ របស់ តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះឡើងវិញ ត្រង់ចំណុចទី៣ "ក" , ៤ , ចំណុចទី៥ ត្រង់រក្សាផ្លូវ ១,៨០ម គុណ ៤,១០ម ប្រើប្រាស់រួម និង ចំណុចទី ៦ នៃ សាលក្រមរបស់តុលាការក្រុងភ្នំពេញ និង ចំណុចទី ៤ នៃ សាលដីការបស់សាលាឧទ្ធរណ៍ ។

៦_រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៣៨.០០០រ,០០ ដែលគូភាគីបានបង់គឺៈ_

_ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៤.០០០រ,០០ ប៉ុន្តែប្រាក់នេះត្រូវ កាត់ចំនួន ៨០០រ,០០ សម្រាប់ជាវង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

_ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០រ,០០ សរុប ១៩.០០០រ, នៅសល់ ១៩.០០០រ,០០ បង្វិលអោយលោក ជ័យ ស៊ាន វិញ ។

៧_សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ៣០_ ខែ ឧសភា ឆ្នាំ ២០០២ ។